សេចក្តីប្រកាស នូវមូលហេតុនៃមាត្រានេះ គឺដើម្បីការពារ និងភាពល្អប្រសើរនៃសុខភាព, ភាពងាយស្រួល, និងបរិយាកាសនៃពលរដ្ឋកូឡូរ៉ាដូ មិនឲ្យប៉ះពាល់ដល់ផ្សែងបារី ។

## តម្រូវមិនឲ្យមានផ្សែងបារី នៅក្នុងគាអារ

មានសរុបទាំង តែមិនកំរិតចំពោះ :

- កន្លែង និងអាគារសាធារណៈ ដូចជា ជណ្តើរយន្ត, បន្ទប់ទឹក, រោងកុន, សារមន្ទី, បណ្ណាល័យ, សាលារៀន, អាគារសឹក្សា, អាគារអ្នកចូលនិវត្តន៏ និងលំនៅដ្ឋានសំរាប់មនុស្សចាស់ ។
- កន្លែងទទួលភ្ញៀវ, កន្លែងបដិសណ្ឋារកិច្ច, ច្រកដើរ, និងកន្លែងប្រើប្រាស់សម្ភញ្ញនានា ។
- កន្លែងដទៃទៀត ដែលគ្មានអ្នកធ្វើការ ។
- ភោជនិយដ្ឋាន, រង្គសាល, កន្លែងលេងល្បែងក្មេង, កន្លែងលេង billiard និង pool, កន្លែងលេង bowling, ផ្សារលក់ទំនិញ និងកន្លែងលក់អាហារដទៃទៀត ។
- កន្លែងលេងកីឡានៅក្នុងអាគារ, កន្លែងហាត់ប្រាណ, កន្លែងស្តាប់ការប្រជុំ ។
- មន្ទីថែរសុខភាព, មន្ទីពេទ្យ, គិលានដ្ឋាន, ការិយាល័យវេជ្ជបណ្ឌិត និងកន្លែងមើលក្មេង ។
- សណ្ឋាគារ និងផ្ទះសំណាក់នានា ដែលបានជួលបន្ទប់មិនតិចជាង ៧៥% ។
- បន្ទប់រង់ចាំ និងធ្វើសេចក្តីសំរេចចិត្តរបស់គណៈវិនិច្ឆ័យ, បន្ទប់សាលាដំបូង និងបន្ទប់ប្រជុំសាធារណៈ
- យានយន្តគ្រប់សណ្ឋានរបស់រដ្ឋាភិបាល ។

## ច្រកចូល

- ច្រកចូលនានាដែលនៅក្រោមច្បាប់នេះ ហាមមិនឲ្យមានផ្សែងបារីជាដាច់ខាត ។
- " ច្រកចូល" មានន័យថា ផ្នែកខាងក្រៅទ្វារ ឬច្រកចូលនៅមុខអាគារ ។ ច្រកចូល មានសរុបទាំងកន្លែងសាធារណៈ ឬកន្លែងឯកជន ដែលមានចំណុចចំងាយនៅខាងក្រៅមាត់ទ្វារ ។ ចំណុចចំងាយ មានកំរិតទៅតាមអ្នកមានសមត្ថកិច្ច ឬ ប្រសិនបើអ្នកមានសមត្ថកិច្ចមិនបានកំរិតមាត្រាទេ កំរិតនៃចំណុចចំងាយនោះ ប្រវែងប្រមាណ ១៥ហ្វីត ។
- ក្រសួងមានសមត្ថកិច្ច ប្រហែលជាកំរិតចំណុចចំងាយ ប្រមាណមិនតិចជាង ១៥ហ្វីត នៅចន្លោះមាត់ទ្វារចូល ។

## អញ្ញត្រកម្ម

- លំនៅឯកជន, លំនៅឋាន, រថយន្ត លើកលែងតែរថយន្តសំរាប់ដឹកក្មេងមកមើល ឬមកថែរក្សា ។
- ជួលរថយន្ត Limousines ដឹកជាឯកជន ។
- បន្ទប់សណ្ឋាគារ ឬផ្ទះសំណាក់ ជួលដល់ទៅ ២៥% ។
- កន្លែងលក់ថ្នាំជក់រាយ ។
- កន្លែងទើបនឹងបង្កើតឡើង មានទាក់ទងជាមួយ "បារជក់បារី-ថ្នាំ" ក្រោយពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៥ ។
- ផ្នែកខាងក្រៅនៃអាគារជំនួញនានា, លើកលែងតែច្រកចូលនានា ដូចបានរៀបរាប់ខាងលើ ។
- ជាន់ទំនេរនានា នៃកន្លែងលេងល្បែង (Casino)។
- ទាំងកន្លែងនៅជុំវិញ ឬកន្លែងដាច់ឡែក ដែលមានបឹតផ្សែងចេញនៅអាកាសយានដ្ឋាន នៅឯអាកាសយានដ្ឋានអន្តរជាតិ Denver (DIA) ។
- ម្ចាស់ហាង ដែលមានកម្មករបីនាក់ ឬតិចជាងនេះ មិនមានកន្លែងសាធារណៈ ។
- អាគារឯកជន, អាគារមិនមានពលរដ្ឋរស់នៅ នៅតាមស្រែចំការ ដែលមានប្រាក់ចំណូលតិចជាង $500,000 ក្នុងមួយឆ្នាំ ។

## ការពិន័យ

ការល្មើសជាមួយនឹងច្បាប់នេះ មានកំរិត ទោសកម្មបន្ថិចបន្តួច ថ្នាក់ទី២ ។

- ជនណាដែលមានជា កម្មសិទ្ធ, ចាត់ចែង, ប្រតិបត្តិការណ៏ ឬក៏ត្រួតត្រា នូវការប្រើប្រាស់ប្រធាននានានៃច្បាប់ ឲ្យមានការល្មើសនឹងច្បាប់បានចែងមក វាជាការល្មើសច្បាប់មួយ ។
- ជនណាជក់បារីនៅក្នុងកន្លែងច្បាប់បានហាមប្រាម វាជាការល្មើសច្បាប់ ។
- ការល្មើសទី១ នៅក្នុងរយៈកាលមួយឆ្នាំ - ពិន័យ $200
- ការល្មើសទី២ នៅក្នុងរយៈកាលមួយឆ្នាំ - ពិន័យ $300
- ការល្មើសទី៣ នៅក្នុងរយៈកាលមួយឆ្នាំ - ពិន័យ $500

ការល្មើសច្បាប់ បន្តមួយថ្ងៃទៅមួយថ្ងៃទៀត ត្រូវចាត់ជាការល្មើសដោយឡែកមួយទៀត ។

## ការប្រតិបត្តិ

- ច្បាប់នេះ ត្រូវបានប្រតិបត្តិដោយក្រសួងមានសមត្ថកិច្ចក្នុងស្រុក ។